**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 11:23
CMS/CFO: Uch Arun

<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជជ

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម៖ បារាំង
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១

<u>ចំណាត់ថ្នាក់ឯកសារ</u>
ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

# ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មតាមវិធាន ៨៩ (ការអនុគ្រោះទោស និងការលើកលែងទោស)

---

**<u>ដាក់ដោយ៖</u>**

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ៖</u>**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**<u>សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៖</u>**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND

**<u>ដាក់ជូន៖</u>**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**<u>ចំលងជូន ៖</u>**

**សហព្រះរាជអាជ្ញា ៖**

ជា លាង

Françoise GAUTRY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Barnabé NEKUIE
Elisabeth RABESANDRATANA
Fabienne TRUSSES NAPROUS

Andrew CAYLEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត**

ហុង គឹមសួន
ឡោ ជុនធី
ស៊ីន សុវ៉ន
សំ សុគង់
វ៉ែន ពៅ
ទី ស្រ៊ីនណា
ជេត វណ្ណលី
Silke STUDZINSKY
Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Marie GUIRAUD
Emmanuel JACOMY
Madhev MOHAN
Lyma Thuy NGUYEN
Julien RIVET
Nushin SARKARATI

**<u>ជនជាប់ចោទ</u>**

អៀង សារី

**សហមេធាវីការពារក្តីជនជាប់ចោទ**

អាង ឧត្តម
Michael G.KARNAVAS

**សហមេធាវីការពារក្តីជនជាប់ចោទផ្សេងទៀត**

## I. រំលឹកអង្គហេតុ និងនីតិវិធី

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានសម្រេចបញ្ជូនខ្លួនជនជាប់ចោទទាំង បួនរូបទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ដ)[1]។

២. នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សារណៈមួយ ស្តីពីការដាក់អញ្ញត្រកម្មបន្ថែម (ការលើកលែងទោស/ការអនុគ្រោះទោស) ដោយបង្គាប់ឲ្យមេធាវីការពារក្តីលោក អៀង សារី បញ្ជាក់ឲ្យបានច្បាស់ថា តើការលើកលែងទោស/អនុគ្រោះទោសលើ អៀង សារី ស្របតាមរដ្ឋធម្មនុញ្ញ ត្រង់មាត្រា២៧ និងមាត្រា៩០ ថ្មីដែរឬទេ ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ដល់មេធាវីការពារក្តីក្នុងការដាក់សារណាមិនឲ្យហួស ពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ និងដល់គ្រប់ភាគី ធ្វើការឆ្លើយតបមិនឲ្យលើសពីថ្ងៃ ច័ន្ទ ទី០៦ ខែមិថុនា ឆ្នាំ២០១១[2] ។

៣. សហមេធាវីនាំមុខក៏បានស្នើសុំពន្យាពេលដាក់ឯកសារនៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១១ ដោយសម្អាងលើមាត្រា៨.៣ និង៨.៥នៃសេចក្តីណែនាំអនុវត្តដាក់ឯកសារនៅចំពោះមុខតុលាការ។

៤. នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានយល់ព្រមផ្តល់រយៈពេលបន្ថែម ដល់បណ្តាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការដាក់សារណារខាងលើមិនឲ្យលើសពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ។

## ១. សេចក្តីផ្តើម

៥. ដូច្នេះដោយអនុលោមតាមវិធាន៨៩(២) នៃវិធានផ្ទៃក្នុង និងមាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខតុលាការ និងអនុស្សារណៈចេញដោយអង្គជំនុំជម្រះ សាលាដំបូង សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការដាក់ចម្លើយតបនឹងសារណាបន្ថែម របស់លោក អៀង សារី ស្តីអំពីអញ្ញត្រកម្មស្របតាមវិធាន៨៩ (ព្រះរាជក្រឹត្យស្តីពីការអនុគ្រោះទោស និងការលើកលែងទោស) ដូចតទៅ៖ លើវាក្យស័ព្ទ លើភាពអនុលោមរបស់ព្រះរាជក្រឹត្យទៅនឹងរដ្ឋធម្មនុញ្ញ និង

1 ដីកាដំណោះស្រាយ ចុះនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D427

2 សូមមើល អនុស្សារណៈនៃអង្គជំនុំជម្រះសាលាដំបូង ស្តីពីការដាក់អញ្ញត្រកម្មបន្ថែម(ការលើកលែងទោស និងការអនុគ្រោះទោស) ឯកសារ E51/8

សុពលភាពរបស់ព្រះរាជក្រឹត្យនេះ ដោយយោងតាម និយាមអន្តរជាតិត្រូវបានទទួលស្គាល់ថាជាវិធានអាជ្ញាបញ្ញា(*jus cogens*) ។

## II. **ការពិភាក្សា÷**

### ក. **លើវាក្យស័ព្ទ**

៦. អត្ថបទជាភាសាខ្មែរនៅតែ ជាមូលដ្ឋានចំបងដើម្បីកំណត់លក្ខណៈសមស្រប របស់ព្រះរាជក្រឹត្យទៅនឹងរដ្ឋធម្មនុញ្ញ ។ ក្នុងភាសាខ្មែរពាក្យថាការលើកលែងទោស[3] សំដៅលើន័យ អនុគ្រោះទោស ដែលបកជាភាសាអង់គ្លេសថា Pardon និងជាភាសាបារាំងថា Grâce ហើយវាមិនមាន ភាពស្រពិចស្រពិល ណាមួយទាល់តែសោះត្រង់ចំនុចនេះ ។ រីឯពាក្យថា ការលើលែងទោសជាទូទៅ[4] សំដៅ លើន័យ Amnesty ជាភាសាអង់គ្លេស និង Amnistie ជាភាសាបារាំង។

៧. មាត្រា ៦ នៃច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ចុះនៅថ្ងៃទី៧ ខែ កក្កដា ឆ្នាំ១៩៩៤ ចែងថា ចំពោះមេដឹកនាំក្រុម“កម្ពុជាប្រជាធិបតេយ្យ” មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ ។

៨. វាគ្មានមន្ទិលសង្ស័យអ្វីទាល់តែសោះ តាមរយៈការសិក្សាលើដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតដែលថា លោក អៀង សារី គឺជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ នៃកម្ពុជាប្រជាធិបតេយ្យ[5]។ ដូច្នេះ លោក អៀង សារី មិនអាចទទួលបានការអនុគ្រោះទោស ពីព្រះរាជក្រឹត្យណាមួយឡើយ និងចេញពីការណ៍នេះ ព្រះរាជក្រឹត្យចុះនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៦នេះ មិនអាច យកមកជំទាស់ទៅនឹងសមត្ថកិច្ច នៃ អ.វ.ត.ក នោះទេ។

### ខ. **លើភាពអនុលោមរបស់ព្រះក្រឹត្យទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

៩. រដ្ឋធម្មនុញ្ញបានចែងពី ការបែងចែកអំណាចយ៉ាងច្បាស់ ក្នុងមាត្រា ២៧ និងមាត្រា ៩0ថ្មី៖
មាត្រា២៧ ចែងថា ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូបន្ថយទោស **និងលើកលែងទោសជាទូទៅ** ។

មាត្រា៩0ថ្មី ចែងថា រដ្ឋសភាអនុម័តច្បាប់ស្តីពី**ការលើកលែងទោសជាទូទៅ**™។

---

[3] សូមមើល អត្ថបទជា ភាសាខ្មែរ មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ

[4] សូមមើលឯកសារភាសាខ្មែរ មាត្រា៩0ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា៧វាក្យខណ្ឌក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[5] ដីកាដំណោះស្រាយ ចុះនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២0១0, ឯកសារ D427 កថាខណ្ឌ ៩៤៤ ដល់ ១0១៧
ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មតាមវិធាន ៨៩ (ព្រះរាជក្រឹត្យអនុគ្រោះទោស និងការលើកលែងទោស)

១០. តាមរយៈការអានបទបញ្ញត្តិទាំងនេះ ការអនុគ្រោះទោសដោយព្រះមហាក្សត្រ អាចធ្វើបានត្រឹម តែទោសប្រហារជីវិតបង់ និងការដកហូតទ្រព្យសម្បត្តិ ដែលបានសម្រេចក្នុងសាលក្រមក្នុងឆ្នាំ ១៩៧៩ ប៉ុណ្ណោះ ។ អង្គហេតុលើកឡើងដើម្បីអនុគ្រោះទោស ចំពោះទោសទាំងអស់ ដែលបានចែងដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ មិនស្ថិតនៅ ក្រោម ព្រះសមត្ថកិច្ចនៃអង្គព្រះមហាក្សត្រនោះទេ ។ មាត្រា ៧ នៃច្បាប់ឆ្នាំ១៩៩៤នេះ ធ្វើការយោងតែមួយគត់ លើមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ។ ដូចនេះ យើងអាចយល់ឃើញថា ព្រះរាជក្រឹត្យនេះមិនអនុលោមតាមរដ្ឋធម្មនុញ្ញនោះទេ ។

## គ. លើសុពលភាពនៃព្រះរាជក្រឹត្យយោងតាមបទេណីអន្តរជាតិ

១១. គ្រប់មូលហេតុទាំងអស់ អ.វ.ត.ក បានទទួលសមត្ថកិច្ចសម្រេចលើដែនអនុវត្តនៃការអនុគ្រោះទោស និងការលើកលែងទោសជាទូទៅ ដែលចោទជាបញ្ហាដោយផ្អែកលើមាត្រា ៤០ នៃច្បាប់ស្តីពី អ.វ.ត.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ [6]។

១២. លើសពីនេះ បទល្មើសដែលលោក អៀង សារី អ្នកទទួលខុសត្រូវខ្ពស់បំផុត ត្រូវបានចោទប្រកាន់នៅចំពោះមុខអ.វ.ត.ក[7] ស្ថិតនៅក្រោមវិធានអាជ្ញាបញ្ញា «*Jus Cogens*» នៅកម្រិតថ្នាក់អន្តរជាតិ ។

## III. សេចក្តីសន្និដ្ឋាន

១៣. ដោយឈរលើអំណះអំណាងនៃហេតុផលខាងលើរួចមក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយគោរពដល់ អង្គជំនុំជម្រះសាលាដំបូង ប្រកាសថាអំណះអំណាងដែលលើកឡើងដោយសហមេធាវីការពារក្តី មិនត្រឹមត្រូវ និងគ្មានមូលដ្ឋានច្បាស់លាស់ និងដូច្នេះ ត្រូវច្រានចោលអំណះអំណាងរបស់ភាគីការពារក្តី ។

---

[6] សូមមើល មាត្រា ៤០ថ្មី ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិសោធនកម្ម ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤

[7] សូមមើលដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ D427 ក្នុង កថាខណ្ឌ ១៦១៣
ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មតាមវិធាន ៨៩ (ព្រះរាជក្រឹត្យអនុគ្រោះទោស និងការលើកលែងទោស)

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ១០ មិថុនា ២០១១ | **ពេជ អង្គ**<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | **Elisabeth Simonneau-Fort**<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |
| | **ម៉ុច សុវណ្ណារី**<br>សហមេធាវីជាតិ | ភ្នំពេញ | |
| | **គឹម ម៉េងឃី**<br>សហមេធាវីជាតិ | ភ្នំពេញ | |
| | Fabienne TRUSSES NAPROUS<br>សហមេធាវីអន្តរជាតិ | ភ្នំពេញ | |